ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៤៣៦៣ ព.ណ.ជ.ឯ.ក

ភ្នំពេញ, ថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ២០១៧

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្មមានកិត្តិយស សូមគោរពជម្រាបជូនសាធារណៈជនទាំងអស់មេត្តាជ្រាបថា យោងតាមមាត្រាច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងការចុះបញ្ជី បានតម្រូវឲ្យសហគ្រាសពាណិជ្ជកម្មទាំងអស់មកចុះបញ្ជីដើម្បីតម្កល់លក្ខន្តិកៈនៅក្រសួងពាណិជ្ជកម្ម ឲ្យបាន ១៥ ថ្ងៃ មុនចាប់ផ្តើមធ្វើអាជីវកម្មនៅទីកន្លែងណាមួយ។ បន្ទាប់មកក្រុមហ៊ុននោះ ត្រូវអនុវត្តន៍នីតិវិធីបន្តនៅអគ្គនាយកដ្ឋានពន្ធដារ និងក្រសួង-ស្ថាប័នជំនាញ ដើម្បីចុះបញ្ជីបង់ពន្ធដារ និងសុំការអនុញ្ញាតលើកស្លាកនៅចំពីលើទីស្នាក់ការក្រុមហ៊ុនរបស់ខ្លួន។ ក្នុងករណីក្រុមហ៊ុនមេ មានបំណងចង់បើកសាខានៅតាមបណ្តាខេត្ត គឺត្រូវមានបញ្ជាក់នាមករណ៍(ឈ្មោះ) សាខាក្រុមហ៊ុននោះ ដើម្បីលើកស្លាកនៅលើស្នាក់ការនៃសាខាក្រុមហ៊ុននៅក្នុងខេត្តដែលខ្លួនបានសុំធ្វើអាជីវកម្ម។ ការផ្តល់ឈ្មោះក្រុមហ៊ុន គឺជាការបញ្ជាក់អត្តសញ្ញាណឲ្យនីតិបុគ្គល សំដៅចៀសវាងការជាន់នាមករណ៍គ្នាជាមួយក្រុមហ៊ុនផ្សេង។ ប្រសិនជាមានឈ្មោះស្រដៀងគ្នា ឬអាចធ្វើឲ្យភាន់ច្រឡំឈ្មោះគ្នា បណ្តាលឲ្យមានការតវ៉ានោះក្រុមហ៊ុនដែលចុះឈ្មោះក្រោយគេ ត្រូវលុបឈ្មោះចោលវិញ និងទទួលខុសត្រូវចំពោះមុខច្បាប់។ នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនមានបញ្ជាក់ពីបុគ្គលទទួលខុសត្រូវ មុខរបរ និងប្រភេទអាជីវកម្មជាដើម តែពុំមែនមានន័យថា ការផ្តល់នាមករណ៍ឲ្យក្រុមហ៊ុន នោះមានបង្កប់នូវសិទ្ធិកាន់កាប់អចលនទ្រព្យជាស្វ័យប្រវត្តិ នោះឡើយ។

ករណីក្រុមហ៊ុនសុខាអូតែល ដែលបានស្នើសុំបើកសាខាក្រុមហ៊ុន និងប្តូរនាមករណ៍ពី **សាខាក្រុមហ៊ុន សុខាអូតែល "ឋានសួគ៌បូកគោ"** ទៅជា **សាខាក្រុមហ៊ុន សុខាអូតែល "សុខាឋានសួគ៌"** គឺក្នុងគោលបំណងបញ្ជាក់ថា **ក្រុមហ៊ុន សុខា អូតែល មានសាខាធ្វើអាជីវកម្មនៅតាមខេត្ត។** ចំពោះការលើកស្លាកគឺត្រូវលើកនៅលើអគារជាទីស្នាក់ការសាខាក្រុមហ៊ុនរបស់ខ្លួនតែប៉ុណ្ណោះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អាជ្ញាធរមានសមត្ថកិច្ចបំពេញបែបបទពន្ធដារ និងនីតិវិធីនានា ស្របតាមច្បាប់កំណត់។

ការអនុញ្ញាតដោយក្រសួងពាណិជ្ជកម្ម កាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ កន្លងទៅគឺជាការអនុញ្ញាតឲ្យប្តូរនាមករណ៍(ឈ្មោះ) របស់សាខាក្រុមហ៊ុនសុខាអូតែលតែប៉ុណ្ណោះ មិនមែនប្តូរឈ្មោះរមណីយដ្ឋានបូកគោទេ។ **ក្រសួងពាណិជ្ជកម្ម ពុំមានសិទ្ធិឲ្យក្រុមហ៊ុន សុខាអូតែល ប្តូរឈ្មោះរមណីយដ្ឋានប្រវត្តិសាស្ត្រដែលបានកំណត់ដោយព្រះរាជក្រឹត្យ នោះឡើយ។**

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណៈជនមេត្តាជ្រាប និងផ្អាកការបំភ្លៃការពិតដើម្បីកេងចំណេញយកផលប្រយោជន៍ផ្ទាល់ខ្លួន ឬបក្សពួកខ្លួន និងបង្កចលាចលដល់សង្គមទៀត។

**សូមអរគុណ**

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA* *Phone/Facsimile: (855)-23 866 469*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**

**លេខ** ០៥៤៧ **ពណ.ចបព**

**ភ្នំពេញថ្ងៃទី** ០១ **ខែ** កញ្ញា **ឆ្នាំ** ២០១៧

# រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
## ជំរាបមក

អ្នកឧកញ៉ា **សុខ គង់** ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន **សុខា អូតែល**
អាសយដ្ឋាន : លេខ ២២ ផ្លូវក្រមួនស (១១៤) សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**<u>កម្មវត្ថុ</u>** : ករណីសុំផ្លាស់ប្តូរនាមករណ៍សាខារបស់ក្រុមហ៊ុន **សុខា អូតែល** " **សុខាថានសួគ៌** "
BRANCH OF SOKHA HOTEL " SOKHA THANSUR "

**<u>យោង</u>** : -សំណើរបស់ក្រុមហ៊ុនលេខ ២១៧ ស.អ ចុះថ្ងៃទី ១០ - ០៨ - ២០១៧

តាមកម្មវត្ថុនិងយោងខាងលើខ្ញុំសូមជំរាបអ្នកឧកញ៉ាថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការប្តូរនាមករណ៍សាខារបស់ក្រុមហ៊ុន **សុខា អូតែល** SOKHA HOTEL CO., LTD. ដែលបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ ០០០០៦៣៣៣ ចុះថ្ងៃទី ២៥ - ០២ - ១៩៩៨ ទៅតាមសំណើដូចខាងក្រោម :

-ការប្តូរនាមករណ៍របស់សាខាក្រុមហ៊ុន :

-នាមករណ៍ចាស់ : **សាខាក្រុមហ៊ុន សុខា អូតែល " ថានសួគ៌បូកគោ "**
BRANCH OF SOKHA HOTEL " THANSUR BOKOR "

មកនាមករណ៍ថ្មី : **សាខាក្រុមហ៊ុន សុខា អូតែល " សុខាថានសួគ៌ "**
BRANCH OF SOKHA HOTEL " SOKHA THANSUR "

ប៉ុន្តែក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនជាមានការតវ៉ាណាមួយទាក់ទងនឹងការផ្លាស់ប្តូរនេះ។

អាស្រ័យហេតុនេះ សូមអ្នកឧកញ៉ាជ្រាប និងអនុវត្តស្របទៅតាមច្បាប់ជាធរមាន ។

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**អនុរដ្ឋលេខាធិការ**

**សុខ_សុគំគ្រៃ**

**<u>ចម្លងជូន</u>** :
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានពន្ធដារ
-នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម
-សាលាខេត្តកំពត
-មន្ទីរពាណិជ្ជកម្មកំពត " មុខការ "
-ឯកសារ-កាលប្បវត្តិ
ធ.រ